# ការសំភាសន៍របស់អ៊ុំប្រុស បៀន ស្រ៊ាន

កៈ អ្នកដែរសំភាសន៍គេមាន ជាងស៊ីអ៊ាវ ខៈ អ្នកដែរអោយគេសំភាសន៍ បៀន ស្រ៊ាន

## ការសង្ខេបប្រវត្តិរបស់អ៊ុំប្រុស បៀន ស្រ៊ាន

អ៊ុំប្រុស បៀន ស្រ៊ាន មានអាយុ74ឆ្នាំនៅក្នុងឆ្នាំ2018 អ៊ុំប្រុស បៀន ស្រ៊ាន មានភេទប្រុស អ៊ុំប្រុស បៀន ស្រ៊ាន មានទីលំនៅបច្ចុប្បន្ននឹងភូមិភូមិព្រែកតានូហៅភូមិបឹងកំប្លោក សង្កាត់ចាក់អង្រែលើ ខ័ណ្ឌចំការមន នៅរាជធានីភ្នំពេញ។

កៈ ចឹងជាដំបូងខ្ញុំសូមអរគុណច្រើនអ៊ុំដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់អ៊ុំ ហើយការសំភាសន៍ នេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរដើម្បីទុកអោយកូនចៅ ជំនាន់ក្រោយៗពួកគាត់បានស្គាល់ពីប្រវត្តិរបស់ឪពុកម្ដាយ នឹងប្រវត្តិរបស់ដូចតារបស់ពួកគាត់ ចឹងនៅពេលដែរខ្ញុំបាន សំភាសន៍អ៊ុំហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសអ៊ុំ ចឹងតើអ៊ុំយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ មួយនេះទៅក្នុងវេបសាយរបស់សាលាដែរទេអ៊ុំ?

ខៈ ប្រវត្តិរឿងអីសួរមក

កៈ ប្រវត្តិកាលពីអ៊ុំនៅក្មេងនៅអីចឹងហាសអ៊ុំ?

ខៈ កាលពីក្មេងនឹងខ្ញុំនៅធ្វើជាកសិករ

កៈ ប៉ុន្តែបានដែរតើហីអ៊ុំមិនអីទេណាអ៊ុំ?

ខៈ នឹងហើយ

ក៖ ចឹងសំរាប់ខ្ញុំជាអ្នកដែរសំភាសន៍អ៊ុំខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ ហើយថ្ងៃខែដែរសំភាសន៍មួយនេះត្រូវបាន ធ្វើឡើងនៅថ្ងៃទី21 ខែ3 ឆ្នាំ2018 គឺសំភាសន៍ភូមិព្រៃកតានូ ហៅភូមិបឹងកំប្លោក ចុះឃុំអីគេដែរអ៊ុំនៅនឹង?

ខ៖ ទេនៅនឹងអត់មានឃុំទេនៅនឹងហោស

ក៖ ចឹងមានតែសង្កាត់នឹងតែម្តងនឹង?

ខ៖ មានតែសង្កាត់តែម្តងនឹង ភូមិនឹងសង្កាត់

ក៖ ប៉ុន្តែនៅសង្កាត់ចាក់អង្រែលើ?

ខ៖ នឹងហើយ

ក៖ នៅខ័ណ្ឌចំការមន នៅរាជធានីភ្នំពេញ ចុះអ៊ុំមានឈ្មោះពេញនឹងអ៊ុំឈ្មោះអីគេដែរអ៊ុំ?

ខ៖ ខ្ញុំឈ្មោះប៉ៀន ស្រ៊ាន

ក៖ ឈ្មោះអៀន ស្រ៊ាង?

ខ៖ ឈ្មោះប៉ៀន ស្រ៊ាន

ក៖ ចឹងឈ្មោះប៉ៀន ស្រ៊ាន ចឹងដូចជាមានឈ្មោះហៅក្រៅទេអ៊ុំ?

ខ៖ អត់មានទេ

ក៖ ចុះកាលពីក្មេងនឹងមាននរណាហៅឈ្មោះអ៊ុំអីផ្សេងដែរទេ?

ខ៖ ជំនាន់ណុងវារៀងធម្មតាទេកាលពីនៅក្មេងនឹងដល់ពេលដែរយើងចាស់ទៅគេហៅហើយនឹង

ក៖ អូ៎!បាទគេហៅឈ្មោះធម្មតាណអ៊ុំ?

ខ៖ នឹងហើយនឹង

ក៖ ចុះសព្វថ្ងៃនឹងអ៊ុំអាយុប៉ុន្មានដែរអ៊ុំ?

ខ៖ ខ្ញុំអាយុ74ឆ្នាំហើយ

កៈ អ៊ុ!អ៊ុំអាយុ74ឆ្នាំហោសអ៊ុំ ចុះដូចជាអ៊ុំកើតនៅថ្ងៃខែឆ្នាំណាអ៊ុំមានចងចាំទេ?

ខៈ ខ្ញុំវគ្គដែរនឹងហាស

កៈ ចឹងអ៊ុំវគ្គដែរហោសអ៊ុំ ប៉ុន្តែឆ្នាំវិញអ៊ុំមានដឹងថាអ៊ុំឆ្នាំអីគេដែរទេអ៊ុំ?

ខៈ ខ្ញុំឆ្នាំវកនឹង

កៈ ចឹងអ៊ុំឆ្នាំវកណាអ៊ុំ?

ខៈ បាទនឹងហើយគុណាចែកមើល

កៈ បាទអ៊ុំចឹងអ៊ុំកើតនៅឆ្នាំ1944អ៊ុំ?

ខៈ កើតនៅឆ្នាំ1944ហោស?

កៈ បាទអ៊ុំបាទចុះអ៊ុំកើតនៅណាវិញអ៊ុំ?

ខៈ ខ្ញុំនៅឃុំជ្រោយតាកែវ ស្រុកកោះធំនឹង ខេត្តកណ្តាល

កៈ នៅភូមិអីគេដែរមិញអ៊ុំ?

ខៈ នៅឃុំជ្រោយតាកែវ

កៈ នៅជ្រោយតាកែវ ប៉ុន្តែភូមីអីគេដែរអ៊ុំ?

ខៈ នៅណុងមានភូមិមកពីណាគេដាក់ភូមិជ្រោយតាកែវចឹងតែម្តងនឹង

កៈ នៅភូមិ នឹងឃុំនឹងដែរ?

ខៈ នឹងហើយចឹង

កៈ បាទអ៊ុំចឹងដូចជាអ៊ុំមានបងប្អូនចំនួនប៉ុន្មាននាក់ដែរអ៊ុំ?

ខៈ ខ្ញុំនឹងសព្វថ្ងៃនឹងនៅតែ3នាក់ទេនឹង

កៈ អូ៎!បាទអ៊ុំចុះពីមុននឹងអ៊ុំមានបងប្អូនចំនួនប៉ន្មាននាក់ដែរទៅអ៊ុំ?

ខៈ ពីមុននឹងបងប្អូន5-6នាក់ដែរនឹង

កៈ ប៉ុន្តែពួកគាត់បានស្លាប់អស់ហើយណាអ៊ុំ?

ខ៖ ប៉ុន្តែបានស្លាប់អស់ហើយនឹងនៅសល់តែ3នាក់ទេនឹង

ក៖ អូ៎!ប៉ុន្តែអ៊ុំជាកូនទីប៉ុន្មានដែរអ៊ុំ?

ខ៖ ខ្ញុំបងគេ

ក៖ ប៉ុន្តែដូចជាមានស្រីប៉ុន្មាននាក់ នឹងប្រុសប៉ុន្មាននាក់ទៅអ៊ុំ?

ខ៖ មានស្រីមួយនាក់ នឹងប្រុសមាន4នាក់នឹង

ក៖ មានប្រុស4នាក់ នឹងស្រីមួយនាក់ ចឹងមានន័យថាមាន5នាក់ណាអ៊ុំ?

ខ៖ ទេមាន6នាក់

ក៖ ចឹងមាន6នាក់មែនទេអ៊ុំមានស្រី1នាក់ នឹងប្រុស5នាក់អ៊ុំ?

ខ៖ នឹងហើយនឹង

ក៖ ចុះអ៊ុំអាចប្រាប់ឈ្មោះពួកគាត់ខ្លះបានទេថាពួកគាត់មានឈ្មោះអីប្អូនរបស់អ៊ុំហាស?

ខ៖ ប្អូនរបស់ខ្ញុំនឹងឈ្មោះបៀននឹងហាស

ក៖ ប្អូនរបស់អ៊ុំនឹងឈ្មោះ?

ខ៖ ប្អូននឹងឈ្មោះស្រូវ នឹងឈ្មោះកុក ឈ្មោះច្រាំង ឈ្មោះចិន ឈ្មោះស្រេ

ក៖ អូ៎!បាទអ៊ុំបាទ?

ខ៖ ខ្ញុំច្រឡំដែរនឹង

ក៖ ចុះអ៊ុំដូចជាមានធ្លាប់ចាំថាកាលពីក្មេងមានប្រវត្តិអីដើរលេងជាមួយគាត់ដូចជាលេងបិទពួន នឹងលេងឡឹកបាយឡអីជាមួយគាត់ដែរទេអ៊ុំ?

ខ៖ លេងកាលពីក្មេងនឹងលេង

ក៖ មានលេងអីគេខ្លះដែរអ៊ុំ?

ខ៖ លេងបិទពួននឹងហាស លេងអួមអីនឹងហាស

ក៖ ប៉ុន្តែមានលេងឡឹកបាយឡមានលេងអីទៀតទេអ៊ុំ?

ខ៖ ទេកាលណុងគ្មានលេងអីទេ

ក៖ បាទប៉ុន្តែអ៊ុំធ្លាប់បានទៅស្រែជាមួយគាត់ដែរទេអ៊ុំ?

ខ៖ ខ្ញុំជាអ្នកធ្វើស្រែនឹងហើយជាមួយឪពុកនឹងជាមួយម្ដាយរបស់ខ្ញុំនឹងហាស

ក៖ បាទអ៊ុំចុះអ៊ុំគិតថាអ៊ុំចូលចិត្តលេងអីគេដែរជាមួយប្អូនរបស់អ៊ុំដែរនឹង?

ខ៖ មិនសូវបានលេងប៉ុន្មានដែរទេនឹង

ក៖ ដូចលក្ខណៈថាទៅស្រែទៅហៃលទឹក ចាប់ក្ដាមចាប់ត្រីអីចឹងហាស?

ខ៖ ធ្វើចំការនឹងធ្វើស្រូវអីនឹង

ក៖ អូ៎!!ទៅជាមួយពួកគាត់ដែរណាអ៊ុំ?

ខ៖ នឹងហើយនឹង

ក៖ បាទអ៊ុំបាទ?

ខ៖ មិនសូវមានពេលលេងទេ

ក៖ បាទចុះអ៊ុំគិតថាប្អូនរបស់អ៊ុំនឹងសព្វថ្ងៃនឹងគាត់នៅណាដែរអ៊ុំ?

ខ៖ នៅស្រុកនឹងហោស

ក៖ អូ៎!នៅស្រុកហោសអ៊ុំ?

ខ៖ បាទនៅភូមិជ្រោយតាកែវនឹងហាស

ក៖ ទាំងអស់គ្នាតែម្ដងនឹងហោសអ៊ុំ?

ខ៖ អាមួយនឹងមកនៅព្រែកស្ដី

ក៖ ព្រែកស្ដីនឹងនៅណាដែរអ៊ុំ?

ខ៖ នៅត្រើយខាងលិចនឹង មួយនៅត្រើយខាងកើតមួយនឹងនៅត្រើយខាងលិច

ក៖ ប៉ុន្តែនៅស្រុកកោះធំនឹងទាំងអស់គ្នានឹង?

ខ៖ បាទនៅស្រុកកោះធំនឹង

កៈ អូ!!បាទអ៊ុំចុះប៉ុន្តែពួកគាត់ធ្វើអីគេដែរនៅណុងអ៊ុំ?

ខៈ ឪពុកម្តាយនឹងស្លាប់អស់ហើយនឹងនៅតែខ្លួនវានឹងនៅមេម៉ាយនៅជាមួយកូននឹង

កៈ អូបាទអ៊ុំ ប៉ុន្តែពួកគាត់ធ្វើអីគេដែរនៅណុងអ៊ុំ?

ខៈ អត់មានរកស៊ីអីទេកូននឹងរកស៊ីចិញ្ចឹមនឹងដូចខ្ញុំចឹង

កៈ បាទអ៊ុំបាទត្រូវអ៊ុំ ចុះម្តាយរបស់អ៊ុំនឹងគាត់ធ្វើអីគេដែរអ៊ុំ?

ខៈ គាត់ឈ្មោះអៀមនួន

កៈ ចុះគាត់ឥឡូវនឹងគាត់អាយុប៉ុន្មានដែរអ៊ុំមានដឹងទេ?

ខៈ គាត់ស្លាប់បាត់អស់ហើយនឹង

កៈ អូ!ប៉ុន្តែគាត់កើតនៅណាដែរអ៊ុំមានដឹងអត់?

ខៈ នៅជ្រោយតាកែវនឹងដែរនឹង

កៈ អូ!បាទអ៊ុំ ចុះឪពុករបស់អ៊ុំនឹងគាត់ឈ្មោះអីគេដែរអ៊ុំ?

ខៈ ហាសថាម៉េច?

កៈ ឪពុករបស់អ៊ុំហាសឈ្មោះអីគេដែរអ៊ុំ?

ខៈ ឈ្មោះប៉ៀន នឹង

កៈ ចុះឈ្មោះអីគេដែរប៉ៀនហាសអ៊ុំ?

ខៈ ខ្ញុំវគ្គដែរហើយនឹង

កៈ ចឹងអ៊ុំភ្លេចហើយណាអ៊ុំ?

ខៈ បាទនឹងភ្លេចដែរ

កៈ ប៉ុន្តែដឹងតែឈ្មោះប៉ៀននឹង?

ខៈ នឹងហើយចឹង

កៈ ប៉ុន្តែគាត់កើតនៅណាដែរអ៊ុំមានដឹងអត់អ៊ុំ?

ខ៖  គាត់នៅស្រុកស្រែនឹងនៅខាងណុងគេហៅស្រុកអីទេនៅខាងស្រុកបាឡីនឹង

ក៖  អូ៎!បាទអ៊ុំ
ចុះឪពុករបស់អ៊ុំនឹងកាលពីគាត់នៅរស់គាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរអ៊ុំ?

ខ៖  គាត់ធ្វើស្រែចំការនឹងហាស

ក៖  ប៉ុន្តែគាត់មានធ្លាប់លក់ដូរអីមួយក៏ធ្លាប់ឡើងត្នោតឡើងអីទេអ៊ុំ?

ខ៖  អត់មានទេ

ក៖  ចឹងគាត់ធ្វើតែស្រែចំការទេណាអ៊ុំ?

ខ៖  នឹងហើយចឹង

ក៖  អូ៎!បាទអ៊ុំ ចុះឪពុករបស់អ៊ុំនឹងគាត់កាចរឺមួយក៏ស្លូតដែរអ៊ុំ?

ខ៖  គាត់ដូចថាកាចមិនកាចរឺស្លូតមិនស្លូតប៉ុន្មានដែរនឹង

ក៖  ចឹងគាត់ធម្មតាណាអ៊ុំ?

ខ៖  នឹងហើយចឹង

ក៖  អូ៎!បាទអ៊ុំ ចុះម្តាយរបស់អ៊ុំនឹងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរអ៊ុំ?

ខ៖  គាត់ធ្វើតែស្រែចំការនឹងតែម្តងនឹង

ក៖  អូ៎!ប៉ុន្តែគាត់កាចរឺមួយក៏ស្លូតដែរអ៊ុំ?

ខ៖  គាត់ធម្មតាដែរនឹងហាស

ក៖
ចុះអ៊ុំមានចងចាំថាកាលពីអ៊ុំនៅជាមួយឪពុកម្តាយរបស់អ៊ុំនឹងតើអ៊ុំធ្លាប់បានធ្វើអីគេជាមួយគាត់ដែរទេ នឹងអ៊ុំ កាលនៅជាមួយគ្នាហាស?

ខ៖  អត់មានធ្វើអីទេធ្វើតែស្រែនឹងហាស

ក៖  ចឹងធ្វើតែស្រែទេណាអ៊ុំ?

ខ៖  នាំគ្នាព្រួតដៃជាមួយម៉ែឪនឹងធ្វើតែស្រែចំការនឹង

កៈ អូ!!បាទអ៊ុំបាទ

ចុះឪពុករបស់អ៊ុំនឹងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិរបស់គាត់កាលពីគាត់នៅក្មេងទៅអ៊ុំដែរទេអ៊ុំ?

ខៈ គ្មានចងចាំទេភ្លេចអស់ហើយនឹងយូរដែរហើយនឹង

កៈ

ចុះម្ដាយរបស់អ៊ុំវិញគាត់មានធ្លាប់ប្រាប៉ពីប្រវត្តិរបស់គាត់នឹងកាលពីក្មេងនឹងទៅអ៊ុំដែរទេ?

ខៈ គាត់ឧស្សាហ៍និយាយដែរគាត់ទៅធ្វើតែស្រែចំការនឹង

នឹងគាត់ប្រដៅកូនចៅរបស់គាត់នមឹងរៀងធ្វើ ស្រែចំការនឹងហាសអោយខំធ្វើនឹង

កៈ បាទអ៊ុំបាទ ចុះយាយតាខាងឪពុកនឹងអ៊ុំមានស្គាល់ឈ្មោះគាត់ដែរទេអ៊ុំ?

ខៈ នឹងដូចជារៀងវគ្គដែរនឹងខ្ញុំមិនសូវច្បាស់ទេនឹង

កៈ ចឹងហោសអ៊ុំ ចុះយាយតាខាងម្ដាយនឹងអ៊ុំមានស្គាល់ឈ្មោះគាត់ដែរទេអ៊ុំ?

ខៈ ស្គាល់ចាំច្បាស់តែយាយនឹង

កៈ យាយឈ្មោះអីគេដែរអ៊ុំ?

ខៈ យាយឈ្មោះយាយសែននឹង

កៈ នឹងខាងឪពុកណាអ៊ុំណា?

ខៈ ខាងម្ដាយទេ

កៈ នឹងខាងម្ដាយហោសអ៊ុំ ប៉ុន្តែយាយតាខាងឪពុកនឹងអ៊ុំអត់ស្គាល់ឈ្មោះគាត់ទេ?

ខៈ ខ្ញុំវគ្គដែរនឹងហាស

កៈ ចុះយាយតាខាងម្ដាយនឹងយាយសែនឹងគាត់នៅណាដែរអ៊ុំ?

ខៈ គាត់នៅស្រុកនៅណុងស្រុកនៅជ្រោយតាកែវនឹងតែម្ដងនឹង

កៈ អូ!ចឹងគាត់នៅកោះធំនឹងដែរហោសអ៊ុំ?

ខៈ បាទនៅណុងដែរនឹង

កៈ ចុះអ៊ុំមកនៅទីក្រុងភ្នំពេញនឹងយូរនៅអ៊ុំ?

ខៈ ខ្ញុំមកនៅឆ្នាំ1993

កៈ អូ៎វានៅឆ្នាំ1993ចឹងវាអស់25ឆ្នាំអ៊ុំ?

ខៈ នឹងហើយ

កៈ បាទចុះអ៊ុំមានបងប្អូនរឺមួយក៏កូនចៅណាដែររស់នៅក្រៅប្រទេសទេអ៊ុំ?

ខៈ អត់មានទេ

កៈ ចឹងមានតែនៅខ្មែរទាំងអស់នឹងហោសអ៊ុំ?

ខៈ បាទនឹងហើយ

កៈ បាទអ៊ុំចុះភរិយារបស់អ៊ុំនឹងគាត់មានឈ្មោះអីគេដែរអ៊ុំ?

ខៈ ភរិយារបស់ខ្ញុំនឹងគាត់ឈ្មោះប៉ែន គេង

កៈ ប៉ុន្តែគាត់នៅរស់សព្វថ្ងៃនឹងតើហីអ៊ុំ?

ខៈ ពួកគាត់បានស្លាប់អស់ហើយនឹង

កៈ
អូ៎!ចុះអ៊ុំមានចងចាំថ្ងៃដែរអ៊ុំបានរៀបអាពាហ៍ពិពាហ៍ជាមួយគាត់ដែរទេដូចថានៅថ្ងៃខែឆ្នាំណាចឹង?

ខៈ ខ្ញុំដូចជាវគ្គហើយនឹងអត់ចងចាំទេ

កៈ ប៉ុន្តែកូនបងរបស់អ៊ុំនឹងគាត់អាយុប៉ុន្មានដែរអ៊ុំឥឡូវនឹង?

ខៈ អាយុជាងហាហើយនឹង

កៈ អូ៎!អាយុជាងហាសិបហើយនឹងអ៊ុំ ដូចជាគាត់អាយុហាប៉ុន្មានដែរទៅអ៊ុំ?

ខៈ គាត់ដូចជាអាយុ53-54ឆ្នាំហើយនឹងតាមមើលនឹង

កៈ ចឹងមានន័យថាអ៊ុំការអស់ជាងហាសិបឆ្នាំជាងហើយណអ៊ុំ?
ខៈ នឹងខ្ញុំចងចាំច្បាស់នឹងការដូចជាអាយុ21ឆ្នាំនឹង

កៈ ចឹងអាយុ21ឆ្នាំហោសអ៊ុំ?

ខៈ បាទនឹងអាយុ20-21ឆ្នាំនឹងទេ

កៈ ប៉ុន្តែអ៊ុំឥឡូវនឹងអ៊ុំអាយុប៉ុន្មានដែរហើយអ៊ុំ?

ខៈ ខ្ញុំអាយុ74ឆ្នាំហើយនឹង

កៈ អ៊ុំអាយុ74ឆ្នាំចឹងមានន័យថាអ៊ុំការអស់ជាង50ឆ្នាំជាងហើយនឹង ចឹងសំរាប់ពេលដែរអ៊ុំចូលស្តី ដណ្តឹងទៅអ៊ុំស្រីនឹងដូចជាមានជាជំនូនទៅអ៊ុំស្រីដែរអ៊ុំកាលពីជំនាន់ណុងហាស?

ខៈ កាលពីជំនាន់ណុងថីមិនមាន

កៈ ចុះមានជាអីគេដែរទៅអ៊ុំពេលណុង?

ខៈ មាននុំនែកអីនឹងហាស នឹងផ្លែឈើអីនឹងហាស

កៈ មាននុំនែកប៉ុន្តែអត់មានជាលុយទេណាអ៊ុំ?

ខៈ និយាយពីរឿងលុយនឹងដូចជាមានហី រឺមួយក៏អត់នឹងខ្ញុំមិនសូវច្បាស់ដែរនឹងរឿងនឹង

កៈ បាទអ៊ុំបាទ ចុះនៅពេលដែរអ៊ុំចូលស្តិដណ្តឹងអ៊ុំស្រីនឹងដូចជាអ៊ុំជាអ្នកចូលស្តីដណ្តឹងដោយខ្លួនឯង រឺមួយក៏ឪពុកម្តាយជាងអ្នករៀបចំអោយដែរអ៊ុំ?

ខៈ ឪពុកម្តាយនឹងអ្នករៀបចំអោយតែម្តងនឹង

កៈ អ៎ូ!!បាទអ៊ុំ ចុះអ៊ុំស្គាល់អ៊ុំស្រីដោយរបៀបណាហាលយហេតុអីបានជាអ៊ុំចូលស្តីដណ្តឹងអ៊ុំស្រីចឹងហាស?

ខៈ របល់យោលអីទេអ្វី

កៈ បាទ?

ខៈ មានអីកាលណុងធ្វើស្រែចំការជិតគ្នានឹងហាស

កៈ ចឹងហោសអ៊ុំប៉ុន្តែអ៊ុំដូចជាអ៊ុំចូលស្តីដណ្តឹងអ៊ុំស្រីប៉ុន្មានឆ្នាំដែរហើយបានអ៊ុំចូលស្តីដណ្តឹងអ៊ុំស្រី?

ខៈ គ្មានចេះលួចស្រលាញ់ទេ

កៈ ពេលដែរឃើញនឹងអ៊ុំចូលស្តីតែម្តងនឹង?

ខៈ នឹងហើយមើលទៅលើម៉ែឪតែម្តងនឹង

កៈ អូ៎!បាទអ៊ុំបាទ ចុះអ៊ុំមានចេះភាសាអីក្រៅពីភាសាខ្មែរដែរទេអ៊ុំ?

ខៈ អត់ទេអត់រៀនផងនឹង

កៈ ប៉ុន្តែអង់គ្លេសអី ចិនអីនឹងអ៊ុំអត់មានចេះទេណាអ៊ុំ?

ខៈ អត់ទេនឹង

កៈ ចុះអ៊ុំរៀនខ្មែរបានថ្នាក់ទីប៉ុន្មានដែរអ៊ុំ?

ខៈ រៀនខ្មែរនឹងបានតិចនឹងខ្ញុំ

កៈ រៀនបានថ្នាក់ទីប៉ុន្មានដែរទៅអ៊ុំ?

ខៈ អានឹងកាលពីយើងនៅជំនាន់មុននឹងគេហៅអីទេកាលពីជំនាន់មុនហាស

កៈ ខ្ញុំអត់សូវដឹងដែរនឹង?

ខៈ គេហៅស្អីទេខ្ញុំភ្លេចបាត់ហើយនឹង

កៈ អូ៎!!អត់អីទេអ៊ុំនិយាយតែអ្វីដែរអ៊ុំចងចាំទៅបានហើយនឹងអ៊ុំ?

ខៈ អើរនឹង

កៈ ចុះអ៊ុំមានចងចាំថាអ៊ុំធ្លាប់មានមិត្តភក្តិដែរស្និទ្ធិស្នាលដែរធំធាត់មកជាមួយគ្នាដែរទេអ៊ុំ?

ខៈ អត់ដែរមានទេ

កៈ ចឹងអត់ដែរមានទេណាអ៊ុំ?

ខ៖ អត់មានទេ

ក៖ ចុះអ៊ុំធ្លាប់ទៅធ្វើស្រែចំការដែរទេអ៊ុំ?

ខ៖ ធ្វើស្រែចំការនឹងធ្វើ

ក៖ អ៊ុំធ្វើរាល់ថ្ងៃណាអ៊ុំ?

ខ៖ នឹងហើយនឹង

ក៖ ប៉ុន្តែដូចជាធ្វើស្រែនឹងអ៊ុំធ្វើអីគេខ្លះដែរអ៊ុំនៅស្រែនឹង?

ខ៖ ធ្វើស្រែធ្វើស្រូវនឹងធ្វើចំការ ដាំពោត ដាំសណ្តែកដាំថ្នាំអីចឹងទៅ

ក៖ អូ៎!នៅស្រែដកស្ទូងច្រូតកាត់អីចឹងហាសណាអ៊ុំ?

ខ៖ នឹងហើយនឹង

ក៖
បាទអ៊ុំចុះអ៊ុំគិតថាតាំងពីក្មេងរហូតមកដល់ពេលនេះហាសតើអ៊ុំធ្លាប់ធ្វើការងារអីគេខ្លះដែរអ៊ុំ
?

ខ៖ អូច្រើនមុខណាស់មានប្រវត្តិតស៊ូនឹងត្រឹមជំនាន់1993នឹង

ក៖ ប៉ុន្តែអ៊ុំគិតថាអ៊ុំធ្លាប់ធ្វើស្រែនឹងបន្ទាប់ពីធ្វើស្រែនឹងអ៊ុំធ្លាប់ធ្វើសំណង់អីទៀតចឹងហាស?

ខ៖ អានឹងពេលដែររត់ទៅនៅភ្នំពេញនឹង

ក៖ ធ្វើអីគេដែរអ៊ុំ?

ខ៖ សំណង់ក៏ធ្វើធាក់ស៊ីខ្លូក៏ដែរនឹង លក់ទឹកអំពៅនឹងក៏ដែរ

ក៖ អូ៎!ចឹងអ៊ុំធ្វើច្រើនហាសណាអ៊ុំ?

ខ៖ មានការតស៊ូ

ក៖ បាទអ៊ុំបាទ ចុះអ៊ុំគិតថាអ៊ុំធ្លាប់បើកអាជីវកម្មលក់ដូរអីទេអ៊ុំ?

ខ៖ អត់មានទេមានតែរកស៊ីតែម្តងនឹង

កៈ  អូ!បាទអ៊ុំបាទ?

ខៈ  មានតែលក់ដូរនឹងតែម្ដងនឹង

កៈ  ចុះអ៊ុំធ្លាប់គិតថាអ៊ុំធ្លាប់ចិញ្ចឹមសត្វទេអ៊ុំដូចជាចិញ្ចឹមមាន់ ទា ជ្រូក គោ ក្របីហាស?

ខៈ  មានពីមុននឹងមាន

កៈ  អ៊ុំចិញ្ចឹមអីគេវិញពីមុននឹង?

ខៈ  ធ្វើស្រែនឹងយើងមិនចិញ្ចឹមគោ

កៈ  បាទអ៊ុំបាទប៉ុន្តែអ៊ុំមានចិញ្ចឹមច្រើនទេអ៊ុំ?

ខៈ  មានចិញ្ចឹមគោ2-3ក្បាលនឹង

កៈ  អូ!បាទអ៊ុំ ចុះអ៊ុំគិតថាតាំងពីក្មេងនឹងជីវិតរបស់អ៊ុំនឹងមានការផ្លាស់ប្ដូរអីទេអ៊ុំ?

ខៈ  ឥឡូវនឹងនេះខ្សោយណាស់

កៈ  អូ!អ៊ុំខ្សោយណាអ៊ុំ?

ខៈ  នឹងហើយនឹង

កៈ  ប៉ុន្តែជីវភាពនឹងយ៉ាងម៉េចដែរអ៊ុំឥឡូវនឹងអ៊ុំធូរជាងមុនរឺក៏យ៉ាងម៉េចដែរអ៊ុំ?

ខៈ  ជីវភាពនឹង

កៈ  ជីវភាពនឹងការរស់នៅអីនឹងហាសអ៊ុំ?

ខៈ  អូ!!អានឹងវាធម្មតាទេអានឹងហោសកូនអ្នកចិញ្ចឹមនឹង

កៈ  អូ!!ចឹងមានន័យថាធូរជាងមុនហើយណាអ៊ុំ?

ខៈ មិនធូរមិនយ៉ាប់មិនតឹងទេនឹងវាល្មមនឹង

កៈ  អូ!!បាទអ៊ុំចុះអ៊ុំចូលចិត្តពិសារម្ហូបអីគេដែរទៅអ៊ុំ?

ខៈ  ឥឡូវនឹងមានតែគ្រៀមគ្រស់ទេនឹង

កៈ  ចុះសម្លម្ជូរ ចៀន ឆា ស្ងោរនឹង?

ខ៖ អានឹងបើកូនចៅធ្វើអោយហូបនឹងចេះតែហូបទៅនឹង

ក៖ ប៉ុន្តែម្ហូបដែរអ៊ុំចូលចិត្តតែម្តងនឹងអីគេដែរអ៊ុំ?

ខ៖ ខ្ញុំចូលចិត្តតែក្រៀមក្រស់នឹងហាស

ក៖ ចូលចិត្តក្រៀមក្រស់នឹងដូចជាសាច់ប្រឡាក់ សាច់អាំងអីចឹងហោសអ៊ុំ?

ខ៖ នឹងហើយចឹង

ក៖ អ៎ូ!!ដូចជាត្រីត្រីងៀតអីនឹងហោសអ៊ុំ?

ខ៖ នឹងហើយចឹង

ក៖ បាទអ៊ុំ
ចុះអ៊ុំគិតថាកាលពីនៅក្មេងនឹងអ៊ុំគិតថាអ៊ុំចូលចិត្តលេងល្បែងប្រជាប្រិយ៍អីគេខ្លះដែរអ៊ុំ?

ខ៖ ខ្ញុំគ្មានទេ និយាយទៅថាអត់មានចឹងតែម្តងនឹងទៅ

ក៖ ប៉ុន្តែអ៊ុំអត់ដែរទៅលេងល្បែងប្រជាប្រិយ៍តាមវត្តដូចចោលឈូង បោះអង្គុញ
ទាញព្រាតអីទេណាអ៊ុំ?

ខ៖ អត់មានទេ

ក៖ អត់ទេហោសអ៊ុំ?

ខ៖ អត់មានទេនឹង

ក៖ អ៎ូ!!បាទអ៊ុំចុះអ៊ុំចេះច្រៀងដែរទេអ៊ុំ?

ខ៖ អត់ចេះទេ

ក៖ ចឹងអ៊ុំអត់ចេះច្រៀងទេ ចុះង៉ុំចូលចិត្តស្តាប់បទចំរៀងទេអ៊ុំ?

ខ៖ ពីមុននឹងចូលចិត្តដែរនឹង ប៉ុន្តែឥឡូវនឹងលែងស្តាប់ហើយនឹង

ក៖ ម៉េចចឹងអ៊ុំ?

ខ៖ ខ្ញុំរកប្រយោជន៍អនាគត់របស់ខ្ញុំដែរនឹង

កៈ អូ!!!បាទអ៊ុំ ចុះអ៊ុំចូលចិត្តស្ដាប់ធិមរឺមួយក៏ទេសស្នាអីទេអ៊ុំ?

ខៈ បាទនឹងស្ដាប់

កៈ ប៉ុន្ដែល្ខោនយីកេអាយៃអីនឹងអ៊ុំចូលចិត្តស្ដាប់ដែរទេ?

ខៈ អានឹងរួមមួយគ្រាៗៗទេអានឹងហោសធម្មតានឹង

កៈ បាទត្រូវអ៊ុំ
ចុះអ៊ុំគិតថាមាននរណាម្នាក់នៅក្នុងក្រុមគ្រួសាររបស់អ៊ុំនឹងចេះលេងឧបករណ៍ភ្លេងដែរទេអ៊ុំមានទេ?

ខៈ គ្មានទេនឹង

កៈ ចឹងអត់មានទេណាអ៊ុំ?

ខៈ បាទនឹងហើយអត់

កៈ ចុះអ៊ុំគិតថាផ្ទះរបស់អ៊ុំនឹងតាំងពីក្មេងរហូតមកដល់ពេលនេះ
ផ្ទះរបស់អ៊ុំនឹងលក្ខណៈបែបណាដែរអ៊ុំ
កាលពីក្មេងនឹងផ្ទះយ៉ាងម៉េចហើយឥឡូវនឹងផ្ទះយ៉ាងម៉េចចឹងហាអ៊ុំ?

ខៈ ឥឡូវនឹងកាលពីមុននឹងខ្ញុំមកនៅឆ្នាំ1993នឹងធ្វើឈើ

កៈ ប៉ុន្ដែដល់ពេលឥឡូវនឹងអ៊ុំ?

ខៈ ឥឡូវនឹងកូនចៅគេធ្វើថ្មនឹង

កៈ ប៉ុន្ដែកាលពីអ៊ុំមកនៅឆ្នាំ1993នឹងធ្វើជាផ្ទះឈើនឹង
អ៊ុំជាអ្នកធ្វើដោយខ្លួនឯងរឺមួយក៏អ៊ុំជួលគេធ្វើអោយ ដែរហោសអ៊ុំ?

ខៈ អានឹងកូនចៅគេជួយនឹង

កៈ ប៉ុន្ដែអ៊ុំមានចេះធ្វើផ្ទះដែរទេអ៊ុំ?

ខៈ បើអោយធ្វើបន្តិចបន្តួចនឹងចេះតែធ្វើបានហើយនឹង

កៈ អូ!!ចឹងសល់ប៉ុន្មាននឹងអ៊ុំជួលគេដែរហោសអ៊ុំ?

ខ៖ បាទនឹងហើយអាណាយើងទៅរួមនឹងយើងធ្វើទៅនឹង

ក៖
អ៊ូ!!បាទអ៊ុំប៉ុន្តែអ៊ុំមានដឹងថាគេធ្វើផ្ទះរបស់អ៊ុំនឹងគេមានប្រើឧបករណ៍អីសំរាប់ធ្វើដែរចឹងហាសអ៊ុំ គេប្រឧបករណ៍អីនឹងសំរាប់សាងសងផ្ទះរបស់អ៊ុំហាស?

ខ៖ រឿងថ្មរឺមួយក៏រឿងឈើដែរ?

ក៖ ផ្ទះឈើហាសផ្ទះអ៊ុំធ្វើលើកមុនហាសអ៊ុំ?

ខ៖ ផ្ទះឈើនឹងយើងមានអីមានតែពន្លាក់ នឹងពូថៅនឹងហាស

ក៖ បាទអ៊ុំបាទនឹង?

ខ៖ មានដែកគោល រណានឹងតែប៉ុណ្ណឹង

ក៖ មានឈើមាន?

ខ៖ អើរឈើនឹងមានតែចឹង យកមកផ្គូរផ្គងដាក់ហើយនឹងយើងអ្នកធ្វើទៅ

ក៖ បាទអ៊ុំបាទចុះអ៊ុំគិតថាអ៊ុំចេះធ្វើផ្ទះតិចតួចនឹងអ៊ុំចេះមកពីនរណាគេដែរអ៊ុំ
ឪពុកម្តាយជាអ្នកបង្រៀនរឺយ៉ាងម៉េចដែរអ៊ុំ?

ខ៖ អានេះយើងដើរធ្វើជាមួយគេនឹងយើងមើលគេនឹងយើងយល់ខ្លះដែរនឹងហាស

ក៖ អ៊ូ!!បាទអ៊ុំត្រូវហើយអ៊ុំ ចុះអ៊ុំគិតថាជំនាញដែរអ៊ុំ?

ខ៖ រឿងជំនាញនឹងមិនប្រាកដទេនឹងស្រេចតែចិត្តនឹកចង់ធ្វើនឹងក៏ធ្វើទៅ

ក៖ បាទអ៊ុំបាទ?

ខ៖ ខុសត្រូវតិចតួចនឹងយើងកែច្នៃទៀតទៅនឹង

ក៖ បាទអ៊ុំបាទ
ចុះអ៊ុំគិតថាឪពុកម្តាយរបស់អ៊ុំនឹងគាត់មានធ្លាប់បង្រៀនពីជំនាញអីទៅអ៊ុំដែរទេ
ដូចជាវេញរល្លី កូរស្កុរ?

ខ៖ មានតែធ្វើស្រែចំការនឹងហាស

កៈ អ៊ូ!!ចុះវេញវល្លិ៍ កូរស្ករ ធ្វើផ្តៅអីនឹងអ៊ុំ?

ខៈ អត់មានទេនឹង

កៈ អត់ដែរមានទេណាអ៊ុំ?

ខៈ បាទអត់មានទេ

កៈ
ចុះអ៊ុំអាចប្រាប់ខ្ញុំបន្តិចពីការលំបាករបស់អ៊ុំតាំងពីក្មេងនឹងរហូតមកដល់ពេលនេះបានទេអ៊ុំធ្លាប់ជួប ការលំបាកអីគេខ្លះដែរចឹងហាសអ៊ុំ?

ខៈ មានលំបាកស្អីបើយើងមានប្រវត្តិរបស់យើងបានដឹងថាធ្វើស្រែចំការនឹងហាស

កៈ បាទអ៊ុំនឹងកាលពីនៅក្មេងនឹង?

ខៈ នឹងហើយនឹង

កៈ ចុះនៅពេល?

ខៈ មិនមែនថាក្មេងទេប៉ុន្តែត្រឹមយើងចេះរកស៊ីមកនឹងយើងដឹង

កៈ ចុះជំនាន់អ៊ុំកើតទាន់ជំនាន់អីសាវ៉ាក់អត់អ៊ុំ?

ខៈ ខ្ញុំមិនសូវដឹងច្បាស់ទេ

កៈ ប៉ុន្តែជំនាន់លុនណុលនឹងអ៊ុំទាន់?

ខៈ ខ្ញុំទាន់ជំនាន់លុនណុល

កៈ ប៉ុន្តែពេលណុងអ៊ុំគេអោយធ្វើអីគេដែរទៅអ៊ុំ?

ខៈ ខ្ញុំអត់មានធ្វើអីទេនឹងខ្ញុំតែរកស៊ីនឹងហាស

កៈ គេអត់មានអោយយើងធ្វើអីផ្សេងទេហោសអ៊ុំ?

ខៈ អត់មានទេនឹងចុះយើងមានធ្វើការងារអីជាមួយរដ្ឋ
យើងធ្វើកសិករធ្វើដោយកំលាំងខ្លួនយើងនឹង

កៈ កាលពីជំនាន់លុនណុលនឹងគេមិនមានប្រើអោយយើងធ្វើអីផ្សេងទេណាអ៊ុំ?

ខ៖ អត់មានទេនឹងយើងមកសម័យពលពតនឹង

ក៖ មកសម័យពលពតនឹងបានយងមានបញ្ហានឹង?

ខ៖ នឹងហើយបានគេប្រើយើងនឹង

ក៖ ប៉ុន្តែកាលពីអ៊ុំនៅជំនាន់លុនណុលនឹងអ៊ុំអាយុប៉ុន្មានដែរអ៊ុំ?

ខ៖ ហ៎!!!បែបជាអាយុ50ឆ្នាំហើយនឹងតាមមើល ដូចជាបើមិនមែន30ឆ្នាំទេអាយុ50ឆ្នាំនឹង

ក៖ មិនមែនណាហីអ៊ុំអាយុ30ឆ្នាំជាងតើហីអ៊ុំ?

ខ៖ ដូចជា30ឆ្នាំជាងនឹងខ្ញុំមិនច្បាស់ដែរទេនឹង

ក៖ អូ៎!!បាទអ៊ុំចុះ?

ខ៖

ចុះយើងគិតមើលប៉ុន្មានឆ្នាំដែរហើយគិតមើលៗៗនឹងមកត្រឹមឥឡូវនឹងហាសជំនាន់លុនណុលនឹង ហាស

ក៖ បាទអ៊ុំបាទវាចូលសឹងតែ50ឆ្នាំហើយនឹងជំនាន់លុនណុលហើយនឹងអ៊ុំ?

ខ៖ ជិត50ឆ្នាំហើយនឹងបើចឹង

ក៖ អាយុការនៅអាយុម្ភៃឆ្នាំជាងអីនឹងហោសអ៊ុំ?

ខ៖ អាយុម្ភៃជាងហើយ ហីអាយុសាមមានតែសាមជាងនឹង

ក៖ អាយុសាមសិបជាងណអ៊ុំ?

ខ៖ នឹងហើយនឹង

ក៖ ចុះកាលពីជំនាន់ពលពតនឹងអ៊ុំអាយុប៉ុន្មានដែរអ៊ុំខ្ទង់សែជាងហើយណអ៊ុំ?

ខ៖ ហ៎!!ខ្ទង់40-50ឆ្នាំអីនឹង

ក៖ បាទអ៊ុំពេលណុងគេជំលាសអ៊ុំទៅណាដែរទៅអ៊ុំ?

ខ៖ ខ្ញុំមុនដំបូងនឹងខ្ញុំនៅភ្នំពេញ ដល់ពេលដែរនៅភ្នំពេញនឹងទៅគេបញ្ជូនខ្ញុំទៅស្រុក ទៅស្រុកកំណើត របស់ខ្ញុំនឹងប៉ុន្តែខ្ញុំអត់នៅភូមិរបស់ខ្ញុំទេ

កៈ បទអ៊ុំប៉ុន្តែគេអោយអ៊ុំ?

ខៈ នៅភូមិគេនឹងហាស

កៈ អោយអ៊ុំធ្វើអីគេដែរអ៊ុំ ពេលណុងនឹង?

ខៈ ធ្វើស្រែនឹង ដល់ពេលដែរអស់ពីធ្វើស្រែនឹងគេដក់ខ្ញុំនឹងរកស្មៅអោយគោ

កៈ ប៉ុន្តែនៅណាដែរអ៊ុំ?

ខៈ នៅស្រុកនឹងហាស

កៈ នៅស្រុកនឹងដដែរនឹង?

ខៈ បាទអត់មានទៅណាឆ្ងាយទេនឹងក្រវិលតែនៅភូមិនឹង

កៈ ប៉ុន្តែធ្វើរហូតនឹងទាល់តែ3ឆ្នាំ នឹង8ខែនឹងហោសអ៊ុំ?

ខៈ នឹងហើយចឹងទាល់តែចប់នឹង

កៈ អ៊្ហូ!!បាទចុះរបបអាហារយ៉ាងម៉េចដែរអ៊ុំ?

ខៈ

ហ៉េ!!!អានឹងចំពោះរឿងខ្ញុំនឹងអត់ខ្វះទេខ្ញុំគ្រប់គ្រាន់ហើយពីព្រោះយើងដើរថ្នាក់ពីប្រធាននឹង

កៈ បាទអ៊ុំបាទ?

ខៈ យងវេចបាយវេចម្ហូបអីនឹងទៅស៊ី

កៈ អ៊្ហូ!!យើងអត់ហូបបបរដូចគេទេណអ៊ុំ?

ខៈ បាទអត់មាននៅកសិដ្ឋាននឹងទេ

កៈ អ៊្ហូ!!ចឹងមានន័យថាអ៊ុំស្រួលហើយចឹងហោស?

ខៈ ខ្ញុំស្រួលអត់មានអីទេ

កៈ អ៊្ហូ!!ចុះពេលណុងឪពុកម្តាយរបស់អ៊ុំនឹងគាត់នៅណាដែរចឹង?

ខៈ ឪពុកម្តាយរបស់ខ្ញុំនឹងគាត់នៅស្រុក

កៈ គាត់នៅស្រុកហោស ប៉ុន្តែយើងនៅបែកគ្នារឺមួយក៏យើងនៅម្នាក់ឯងដែរអ៊ុំ?

ខៈ អត់ទេបែកគ្នាអស់ហើយនឹង

កៈ អូ៎!!ចឹងមានន័យថានៅបែកគ្នាហោស?

ខៈ ខ្ញុំបែកគ្នាជាមួយគាត់តាំងពីឆ្នាំ1993នឹង

កៈ បាទអ៊ុំបាទ?

ខៈ ហើយដល់ពេលដែរជំលាសទៅក៏អត់នៅជាមួយគាត់ដែរ
យើងចេញពីគាត់ទៅទៀតនឹង

កៈ ប៉ុន្តែពួកគាត់គេអោយធ្វើអីគេដែរអ៊ុំ?

ខៈ គាត់ចាស់ៗអស់ហើយនឹងមានធ្វើអីទេមានតែមើលក្មេងនឹងមើលចៅអីនឹងហាស
ខ្ញុំវាមិនសូវ ច្បាស់ដែរនឹងពីព្រោះអត់នៅជាមួយផងនឹង

កៈ បាទអ៊ុំបាទចុះបងប្អូនរបស់អ៊ុំនឹងគេអោយទៅណាដែរទៅ?

ខៈ ប្អូនបងរបស់ខ្ញុំយ៉ាងម៉េច ប្អូនរបស់ខ្ញុំរឺមួយក៏កូនរបស់ខ្ញុំ?

កៈ បាទប្អូនៗហាស?

ខៈ ប្អូនរបស់ខ្ញុំវានៅស្រុកអត់មានទៅណាទេ

កៈ ប៉ុន្តែពេលជំនាន់ពលពតនឹងអ៊ុំមានកូនប៉ុន្មាននាក់ដែរអ៊ុំ?
ខៈ ខ្ញុំនឹងមានកូន3-4នាក់ហើយនឹង

កៈ ប៉ុន្តែពួកគាត់នឹងរៀងធំៗអស់ហើយមែនទេអ៊ុំ?

ខៈ រៀងត្រើសៗដែរហើយនឹង

កៈ អ៎!!ចឹងមានន័ងថាពួកគាត់ក៏ទាន់ជំនាន់ពលពតដែរណាអ៊ុំ?
ខៈ នឹងហើយទាន់

កៈ ចុះអ៊ុំគិតថាដាច់ពីពលពតនឹងចូលជំនាន់អីគេដែរអ៊ុំចូលជំនាន់ខ្មែរក្រហមហីអ៊ុំ?

ខៈ ហ៉ោ!!!អត់ទេពលពតនឹងហើយខ្មែរក្រហមនឹង

កៈ ចឹងហោសអ៊ុំចឹងមានន័យថាដាច់ជំនាន់ពលពតទៅដាច់អស់ហើយណាអ៊ុំ?
ខៈ ដាច់នឹង

កៈ ប៉ុន្តែគ្រាន់តែថាពេលណុងយើងនៅវេទនាពិបាករកលុយរកអីមែនទេអ៊ុំ?

ខៈ នឹងហើយយើងខំធ្វើស្រែយើងវិញហើយនឹងយើងធ្វើផ្ទាល់ខ្លួនរបស់យើងវិញហាស

កៈ ប៉ុន្តែពេលណុងគេចែដីចែកស្រែអោយយើងវិញហើយណាអ៊ុំ?

ខៈ នឹងហើយដល់មកបានគេចែក

កៈ យើងធ្វើម៉េចបានដឹងថាគេចែករបស់មួយនឹងជារបស់យើងអ៊ុំ?

ខៈ ចុះដីនឹងគេប្រមូលយកអស់ហើយគេនឹងមិនចែកតាមគ្រួសាររបស់យើងវិញ

កៈ អ៊ូ!!បាទអ៊ុំ ប៉ុន្តែអ៊ុំពេលណុងអ៊ុំវេទនាដែរតើហីអ៊ុំ?
ខៈ កាលណុងវេទនាដែរនឹងអត់វេទនាក៏ថាបានដែរអានឹងនៅលើកំលាំងរបស់យើងធ្វើនឹង

កៈ
បាទអ៊ុំបាទអ៊ុំគិតថាអ៊ុំឆ្លងកាត់ការវេទនានឹងដោយរបៀបណាដែរអ៊ុំលក្ខណៈពុះពារឧបសគ្គហាស?

ខៈ ខ្ញុំដូចថាកាលពីជំនាន់អាពតនឹងខ្វះជីវភាពរឿងហូបចុកនឹង

កៈ បាទអ៊ុំបាទ?

ខៈ ហើយក្រៅពីនឹងមកដូចជាមានអីធម្មតានឹងហាស

កៈ អ៊ូ!!បាទអ៊ុំ
ចុះអ៊ុំគិតថាពេលណាដែរអ៊ុំគិតថាជាពេលដែរសប្បាយនៅក្នុងឆាកជីវិតរបស់អ៊ុំដែរ?

ខៈ
អត់មានពេលសប្បាយទេសប្បាយទាល់តែថាយើងលែងរកតែម្តងនឹងដេកស៊ីតែម្តងនឹង

កៈ ដូចឥឡូវនឹងអីនឹងហោសអ៊ុំស្រួល?

ខៈ ដូចឥឡូវនឹងអីក៏មិនស្រួលដែរនឹងទាល់តែអស់ជីវិតតែម្តងនឹងបានថាស្រួលនឹង

កៈ  អើរ....ម៉េចចឹងអ៊ុំ?

ខៈ  ចុះបើយើងនៅនឹងយើងនៅគិតតែរកស៊ីនឹងដើម្បីឆ្អែតនឹង

កៈ  អូ៎!!ប៉ុន្តែចង់និយាយថាកូនរបស់អ៊ុំនឹងគាត់ឈប់អោយអ៊ុំធ្វើអីហើយមែនទេអ៊ុំ ប៉ុន្តែអ៊ុំនៅតែខ្វះដដែរនឹងអ៊ុំ?

ខៈ  យើងនៅខ្វះថាយើងអត់លុយចាយ

កៈ  អូ៎!!!បាទអ៊ុំចុះនៅពេលដែរអ៊ុំការនឹងអ៊ុំគិតថាសប្បាយទេអ៊ុំ?

ខៈ  ហោ៎!!តែការហើយនឹងសប្បាយហើយនឹងយើងសប្បាយនាំគ្នារកស៊ីហើយនឹង

កៈ  បាទអ៊ុំ ប៉ុន្តែពេលដែរកូនរបសអ៊ុំការអីនឹងគិតថាសប្បាយទេអ៊ុំ?

ខៈ  បាទនឹងកូនការចឹងទៅគេរកស៊ីគ្រួសាររបស់គេហើយនឹង

កៈ  បាទអ៊ុំបាទ?

ខៈ  គេចិញ្ចឹមគ្នាគេហើយនឹង

កៈ
ចុះអ៊ុំធ្លាប់គិតថាអ៊ុំធ្លាប់មានក្តីសង្ឃឹមថាចង់ធ្វើអីទេកាលពីនៅក្មេងហាសពេលដែរធំឡើងហាស?

ខៈ  ដូចជាគ្មានទេដឹងតែស្រែចំការនឹងតែម្តងនឹង

កៈ  ចុះអ៊ុំពេលដែរអ៊ុំរៀននឹងអ៊ុំធ្លាប់គិតថាអ៊ុំធ្វើជាគ្រូបង្រៀនរឺមួយធ្វើគ្រូពេទ្យអីទេអ៊ុំ?

ខៈ  ខ្ញុំឈោងអត់ដល់ដែរនឹង

កៈ  ប៉ុន្តែអ៊ុំធ្លាប់គិតមួយនឹងដែរណាអ៊ុំ?

ខៈ
យើងទៅអត់ដល់មួយនឹងទេពីព្រោះយើងទៅមិនដល់មកពីយើងគិតគោលបំណងរឿងរកស៊ី

កៈ  ចឹងមានន័យថាគោលបំណងរបស់អ៊ុំកាលពីនៅក្មេងនឹងគឺគិតថាចង់រកស៊ីណាអ៊ុំ?

ខ៖  នឹងហើយ

ក៖
អូ៎!!!បាទអ៊ុំចុះបើសិនជាចង់អោយអ៊ុំផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយៗៗនឹងតើអ៊ុំចង់ផ្ដែផ្ដាំអីទៅពួកគាត់ ដែរអ៊ុំ?

ខ៖
មានផ្ដែផ្ដាំអីហោសយើងមានតែគិតខំរកស៊ីចិញ្ចឹមកូននឹងចិញ្ចឹមចៅយើងចឹងទៅនឹងមានតែប៉ុណ្ណឹង

ក៖
អូ៎!!បាទអ៊ុំបាទចុះបើសិនជាចង់អោយពួកគាត់ជៀសវៀងវិញតើអ៊ុំចង់អោយពួកគាត់ជៀសវៀងអីគេ ដែរទៅអ៊ុំ?
ខ៖  អានឹងពិបាកដែររឿងនឹងពិបាកឆ្លើយតែម្ដងនឹងនៅសម័យនេះពិបាកឆ្លើយដែរនឹង

ក៖  អូ៎!!!ចឹងហោសអ៊ុំអត់អីទេអ៊ុំបើអ៊ុំឆ្លើយមិនកើតក៏មិនអីដែរអ៊ុំ?

ខ៖  បាទនឹងហើយ

ក៖  ចុះអ៊ុំមានអីចង់ផ្ដែផ្ដាំធ្វើម៉េចអោយពួកគាត់អាចរីកចំរើននៅក្នុងសង្គមបានដែរទេអ៊ុំ?

ខ៖  រីកចំរើននឹងទាល់តែយើងខំរកស៊ីនឹងហាស

ក៖  ខំរៀនដើម្បីខំរកស៊ីណាអ៊ុំ?

ខ៖  ខំរៀនយកតំរិះនឹងដើម្បីខំរកស៊ី យើងនៅរៀននឹងយើងយកតំរិះ

ក៖  ដើម្បីធ្វើការរកស៊ីណាអ៊ុំ?

ខ៖  នឹងហើយចឹង

ក៖  អូ៎!!បាទអ៊ុំចុះអ៊ុំមានអីដែរចង់ផ្ដែផ្ដាំអីទៅពួកគាត់ផ្សេងទៀតទេអ៊ុំ?

ខ៖  មានអីហោសគ្មានដែរនឹង

ក៖  ចឹងអត់មានអីត្រូវផ្ដែផ្ដាំទៀតទេណាអ៊ុំ?

ខ៖  នឹងហើយមានដឹងផ្ដែផ្ដាំអីហោសបើថាយើងរើននឹងយើងត្រូវខំរៀនយកតំរិះ

កៈ បាទអ៊ុំបាទ?

ខៈ ដើម្បីចិញ្ចឹមជីវិតរបស់យើងនឹង

កៈ បាទអ៊ុំបាទ?

ខៈ ម៉ែឪនឹងគ្មានអោយអីទៀតទេមានតែចំនេះវិជ្ជានឹងហើយ

កៈ បាទអ៊ុំបាទត្រូវអ៊ុំដោយសារតែ?

ខៈ តែបើយើងអត់រៀននឹងយើងខំរកស៊ីនឹង

កៈ បាទអ៊ុំបាទនឹងដោយសារតែម៉ែឪនឹងខំជួយយើងឆ្អែតឆ្អន់ហើយណាអ៊ុំ?

ខៈ ជួយអោយរៀនហើយនឹងហើយ

កៈ បាទអ៊ុំហើយនឹងពួកគាត់បានចិញ្ចឹមយើងឆ្អែតហើយនឹងអ៊ុំ?

ខៈ បាទនឹងហើយ

កៈ ល្មមយើងរៀនហើយនឹងចេញរកលុយដោយខ្លួនឯងហើយណាអ៊ុំ?

ខៈ នឹងហើយចឹងបាទយើងមានអីមានកេរ្តិ៍អាករណាដែរអោយទៀតនឹង

កៈ បាទអ៊ុំបាទមានអីផ្សេងដែរអ៊ុំចង់និយាយផ្សេងពីនឹងទៀតទេអ៊ុំ?

ខៈ អត់មានទេនឹង

កៈ បាទអ៊ុំបាទ
ចឹងជាចុងក្រោយខ្ញុំអរគុណច្រើនអ៊ុំដែរបានអោយខ្ញុំពិភាក្សាដែរទាក់ទងពីប្រវត្តិរបស់អ៊ុំចឹងហាសអ៊ុំ?

ខៈ បាទនឹង

កៈ
បាទចឹងជាចុងក្រោយខ្ញុំជូនពរអ៊ុំដើម្បីអោយអ៊ុំមានសុខភាពល្អនឹងអាចរីកចំរើននៅក្នុងការរកស៊ី របស់អ៊ុំដែរអ៊ុំប៉ង់ប្រាថ្នាដែរជាគោលបំណងរបស់អ៊ុំចឹងហាសអ៊ុំ
បាទអ៊ុំចឹងអរគុណច្រើនអ៊ុំ៕៕៕